ព្រះរាជក្រម

នស/រកម/១២១១/០១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្មានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាគ្សត្រ
ខេមរាជនា សម្ងហោរាស តម្ពុជឯករាជរដ្ឋបូរណសន្តិ សុតមង្គលា សីរីតិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងតម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែរឿយឡើយ កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់
ស្តីពី
ហិរញ្ញវត្ថុសម្រាប់
ការគ្រប់គ្រងឆ្នាំ ២០១២

ROYAUME du CAMBODGE
MINISTERE du PALAIS ROYAL

ជំពូកទី ១
ថវិកាថ្នាក់ជាតិ

មាត្រា ១.-

ត្រូវបានអនុញ្ញាតសម្រាប់ឆ្នាំ ២០១២ ឲ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិនូវ ពន្ធដារ វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឲ្យសម្រេចនូវឧបត្ថម្ភកធនវិនិយោគ និងការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង "ក" ដែលភ្ជាប់មកជាមួយច្បាប់នេះ: ក្នុងទឹកប្រាក់សរុបចំនួន ១០ ៧៦៧ ៩៨២ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ :

- ចំណូលចរន្ត.....៧ ៣០០ ៦៥៧ លានរៀល
- ចំណូលមូលធន.....៣ ៤៦០ ០០០ លានរៀល
  - + ចំណូលមូលធនក្នុងប្រទេស.....៨០ ០០០ លានរៀល
  - + ចំណូលមូលធនក្រៅប្រទេស.....៣ ៣៨០ ០០០ លានរៀល
    - មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ.....
      .....៥២០ ០០០ លានរៀល
    - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស.....
      .....២ ៨៦០ ០០០ លានរៀល

ប្រើប្រាស់បញ្ជើរាជរដ្ឋាភិបាល.....៧ ៣២៥ លានរៀល

មាត្រា ២.-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ត្រូវបានកំណត់ស្មើនឹង ១០ ៧៦៧ ៩៨២ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ :

- ចំណាយចរន្ត.....៦ ៣៣០ ៦៥៧ លានរៀល
- ចំណាយមូលធន.....៤ ៤៣៧ ៣២៥ លានរៀល
  - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស.....
    .....
    .....១ ៣២៧ ៣២៥ លានរៀល
    - + ដោយថវិកាថ្នាក់ជាតិ.....១ ០២៧ ៣២៥ លានរៀល
      - -គម្រោងវិនិយោគផ្ទាល់.....៨២៧ ៣២៥ លានរៀល
      - បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស
        .....២០០ ០០០ លានរៀល
    - +ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ.....
      .....៣០០ ០០០ លានរៀល



- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស.....
.....២ ៨៦០ ០០០ លានរៀល
- ការទូទាត់ប្រាក់កម្ចី.....២៥០ ០០០ លានរៀល

មាត្រា ៣.-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ត្រូវបានកំណត់ស្មើនឹង ៦ ៣៣០ ៦៥៧ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "ខ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

មាត្រា ៤.-

ចំនួនទឹកប្រាក់នៃឥណទានមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស សម្រាប់ការគ្រប់គ្រងពីឆ្នាំ ២០១២ ដល់ ២០១៤ ត្រូវបានកំណត់ស្មើនឹង ១១ ៥៦៦ ០៥៥ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ តាមគម្រោង និងតាមឆ្នាំ ដូចមានចែងក្នុងតារាង "ក១" និងតារាង "ក២" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

មាត្រា ៥.-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយមូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ត្រូវបានកំណត់ដូចខាងក្រោម :

- ឥណទានភ្ជាប់សន្យា.....៤ ៦៥១ ៤៤៥ លានរៀល
- ឥណទានទូទាត់.....៤ ៤៣៧ ៣២៥ លានរៀល

ឥណទាននេះត្រូវបានបែងចែកដូចតទៅ :

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស :

- ឥណទានភ្ជាប់សន្យា.....១ ៣២៧ ៣២៥ លានរៀល
- ឥណទានទូទាត់.....១ ៣២៧ ៣២៥ លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស :

- ឥណទានភ្ជាប់សន្យា.....៣ ០៧៤ ១២០ លានរៀល
- ឥណទានទូទាត់.....២ ៨៦០ ០០០ លានរៀល

គ. ការទូទាត់ប្រាក់កម្ចី :

- ឥណទានភ្ជាប់សន្យា.....២៥០ ០០០ លានរៀល
- ឥណទានទូទាត់.....២៥០ ០០០ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ ដូចមានចែងក្នុងតារាង "ឃ" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

មាត្រា ៦.-

តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ដែលបានរៀបចំនៅក្នុងតារាង "ក" ស្តីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង "ខ" ស្តីពីចំណាយថវិកាថ្នាក់ជាតិ ត្រូវបានបង្ហាញនៅក្នុងតារាងកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិដូចខាងក្រោម :

ឯកតា : លានរៀល

កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ	ចំនួនទឹកប្រាក់	តុល្យភាព/ហិរញ្ញប្បទាន
I. ចំណូលក្នុងប្រទេស	៧ ៣៨០ ៦៥៧	
១. ចំណូលចរន្ត	៧ ៣០០ ៦៥៧	
២. ចំណូលមូលធនក្នុងប្រទេស	៨០ ០០០	
II. សរុបចំណាយថវិកា	១០ ៥១៧ ៩៨២	
១. ចំណាយចរន្ត	៦ ៣៣០ ៦៥៧	
២. ចំណាយមូលធន (មិនគិតការទូទាត់ប្រាក់កម្ចី)	៤ ១៨៧ ៣២៥	
•វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស	១ ៣២៧ ៣២៥	
- ដោយថវិកាថ្នាក់ជាតិ	១ ០២៧ ៣២៥	
+ គម្រោងវិនិយោគផ្ទាល់	៨២៧ ៣២៥	
+ បដិភាគ	២០០ ០០០	
- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ	៣០០ ០០០	
•វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស	២ ៨៦០ ០០០	
អតិរេកនៃថវិកាចរន្ត (I.១ -II.១)		+៩៧០ ០០០
ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ (I-II)		-៣ ១៣៧ ៣២៥
III. ហិរញ្ញប្បទាននៃឱនភាព		+៣ ១៣៧ ៣២៥
១. ហិរញ្ញប្បទានក្រៅប្រទេស		+៣ ១៣០ ០០០
- មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ		+៥២០ ០០០
- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស		+២ ៨៦០ ០០០
- ការទូទាត់ប្រាក់កម្ចី		-២៥០ ០០០
២. ហិរញ្ញប្បទានក្នុងប្រទេស		+៧ ៣២៥
- បញ្ញើរាជរដ្ឋាភិបាល		+១០៧ ៣២៥
- មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ		-១០០ ០០០

ជំពូកទី ២
ការខ្ចី និងការធានារបស់រដ្ឋ

មាត្រា ៧.-

សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ អនុម័តយល់ព្រមឲ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេក្នុងកម្រិត ៧០០ ០០០ ០០០ S.D.R. (ប្រាំពីរយលានអេសដេអ៊ែ) ។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកម្រិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ ។

នៅក្នុងលក្ខខណ្ឌនេះរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិដាណាយលក្ខណ៍អក្សរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលក្នុងការចុះហត្ថលេខាលើការខ្ចីជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬលើការធានារបស់រដ្ឋ ហើយត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តនៃការខ្ចី និងការធានានេះ ជូនរដ្ឋសភានិងព្រឹទ្ធសភារៀងរាល់ ៦ ខែម្តង ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការឯកភាពពីធនាគារជាតិនៃកម្ពុជាត្រូវបានទទួលការអនុញ្ញាតឲ្យបោះផ្សាយបណ្ណរតនាគារ ក្នុងកម្រិតទឹកប្រាក់ដែលមានស្តុកចំនួន ១០០ ០០០ ០០០ ០០០ រ (មួយរយពាន់លានរៀល) ដើម្បីដោះស្រាយតម្រូវការជាបន្ទាន់ខាងសាច់ប្រាក់ ។ លក្ខខណ្ឌនៃការលក់បណ្ណរតនាគារនេះត្រូវកំណត់ដោយលិខិតបទដ្ឋានស្របច្បាប់ ។

មាត្រា ៨.-

សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ អនុម័តយល់ព្រមឲ្យរាជរដ្ឋាភិបាលឲ្យអគ្គិសនីកម្ពុជាខ្ចីនូវទឹកប្រាក់ចំនួន ១០៧ ៣២៥ ០០០ ០០០ រ (មួយរយប្រាំពីរពាន់បីរយម្ភៃប្រាំលានរៀល) ។

មាត្រា ៩.-

មិនអនុញ្ញាតឲ្យក្រសួង ឬស្ថាប័នសាធារណៈណាមួយចំណុះរដ្ឋមានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្រយៈពេលវែង មធ្យម ខ្លី ឬឥណទានអ្នកផ្គត់ផ្គង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬការធានាកិច្ចសន្យាដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬឯកជន ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ ឬតាមឆ្នាំដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ និងលក្ខខណ្ឌទាំងឡាយដែលច្បាប់នេះបានកំណត់នោះទេ ។

ជំពូកទី ៣
និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ
ថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១

មាត្រា ១០.-

ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានយល់ព្រមជាគោលការណ៍ដូចខាងក្រោម :

ក- ផ្តល់តណាទានថវិកាបន្ថែមដល់ថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ នូវទឹកប្រាក់សរុបចំនួន ២៤១ ១៩១ ៤៥២ ០០០ រៀល ក្នុងនោះ :

- សម្រាប់រៀបចំមហាសន្និបាតអន្តរសភាអាស៊ានអាយ៉ាលើកទី ៣២ របស់រដ្ឋសភា ទឹកប្រាក់ចំនួន ១ ១៩១ ៤៥២ ០០០ រៀល
- សម្រាប់ចំណាយលើការងារអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជារបស់រាជរដ្ឋាភិបាល ទឹកប្រាក់ចំនួន ២២០ ០០០ ០០០ ០០០ រៀល
- សម្រាប់ចំណាយលើការងារគ្រោះទឹកជំនន់របស់រាជរដ្ឋាភិបាល ទឹកប្រាក់ចំនួន ២០ ០០០ ០០០ ០០០ រៀល ។

ខ- សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ អនុម័តយល់ព្រមជូនរាជរដ្ឋាភិបាលឲ្យអគ្គិសនីកម្ពុជាខ្ចីនូវទឹកប្រាក់ចំនួន ២០ ២៥០ ០០០ ០០០ រៀល។

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ នឹងត្រូវអនុម័តនូវចំនួនទឹកប្រាក់ជាក់ស្តែងនៃកិច្ចប្រតិបត្តិការថវិកាបន្ថែមខាងលើនេះ ។

ជំពូកទី ៤
ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២

មាត្រា ១១.-

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ៨៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ និងបទប្បញ្ញត្តិនៃមាត្រា ៥៤ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ត្រូវបានគណនាតាមរូបមន្តខាងក្រោមនេះ :

- សរុបចំណូលថវិកា.....៤២៧ ៨៣០ លានរៀល
  - ចំណូលចរន្ត.....៣៣២ ១៥៤ លានរៀល
    - + ចំណូលសារពើពន្ធ.....៣១០ ១៨៩ លានរៀល
    - + ចំណូលមិនមែនសារពើពន្ធ.....២១ ៩៦៥ លានរៀល
  - ចំណូលមូលធន.....០ លានរៀល
    - + ចំណូលមូលធនផ្ទៃក្នុង.....០ លានរៀល
  - ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ.....៩៥ ៦៧៦ លានរៀល
- សរុបចំណាយថវិកា.....៤២៧ ៨៣០ លានរៀល
  - ចំណាយចរន្ត.....៣៤២ ៨១២ លានរៀល
  - ចំណាយមូលធន.....៨៥ ០១៨ លានរៀល

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមរាជធានីខេត្ត ក្រុង ស្រុកនីមួយៗ ក៏ដូចជាការបែងចែកឥណទាននៅផ្ទៃក្នុងថវិកាជាដំពូក គណនី និងអនុគណនី ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ។

ជំពូកទី៥
អវសានប្បញ្ញត្តិ

មាត្រា ១២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

មាត្រា ១៣.-

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១

ព្រះហស្តលេខា និងព្រះរាជលញ្ឆកររ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមទ្បាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ:១៥៤៧ច.ល
ត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១១
នាយកនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

ម៉ៃ សុខា